**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១០៧៤១ ព.ណ.ស.ជ.ក

ថ្ងៃ ចន្ទ ១៣កើត ខែ ផល្គុន ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ដល់៣១ ខែមីនា ឆ្នាំ២០១៩ នឹងត្រូវលក់ ៣.៨១០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៧១០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី១៦ ដល់៣១ ខែមីនា ឆ្នាំ២០១៩** នឹងចុះមក ៣.៦៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៥៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | **Average MOPS** | ០,៤៤៦៨ ដុល្លារ | ០,៥១១៥ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៧៩១ ដុល្លារ | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | ០,០២៩៦ ដុល្លារ |
| ៣ | **PREMIUM** | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៨២៦ ដុល្លារ | ០,០៨១១ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩០៨៥ ដុល្លារ | ០,៨៩២២ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៦២៥ រៀល | ៣.៥៦០ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩១ ដុល្លារ | ០,៨៩ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៦៥០ រៀល | ៣.៥៥០ រៀល |

សម្គាល់៖ អាត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដែលស្មើនឹង ៣៩៩០រៀល/ដុល្លារអាមេរិក

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង DO 0.05% (USD/Barrel) |
|---|---|---|
| ១ មីនា ២០១៩ | ៦៨,៣៥ | ៨២,៦៤ |
| ៤ មីនា ២០១៩ | ៦៧,៧៧ | ៨១,០៤ |
| ៥ មីនា ២០១៩ | ៦៨,៣៨ | ៨១,០៩ |
| ៦ មីនា ២០១៩ | ៦៩,៦៥ | ៨១,០៥ |
| ៧ មីនា ២០១៩ | ៧១,២៩ | ៨១,៣៨ |
| ៨ មីនា ២០១៩ | ៧០,៤០ | ៨០,៨៩ |
| ១១ មីនា ២០១៩ | ៧២,១១ | ៨១,៥៧ |
| ១២ មីនា ២០១៩ | ៧២,៧២ | ៨១,៤១ |
| ១៣ មីនា ២០១៩ | ៧២,៥៨ | ៨០,៨៦ |
| ១៤ មីនា ២០១៩ | ៧៤,៥៥ | ៨១,៣៩ |
| ១៥ មីនា ២០១៩ | ៧៣,៦២ | ៨១,២៥ |
| **មធ្យមភាគ ១១ថ្ងៃ** | ៧១,០៣៨២ | ៨១,៣២៤៥ |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | ០,៤៤៦៨ | ០,៥១១៥ |

សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់ ។